ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាល

លេខ :...០៧៦ សជណ/អរប

ថ្ងៃ...............ខែ.............ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ កុម្ភៈ ឆ្នាំ២០២៥

# សូមជម្រាបជូន

## ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត

**កម្មវត្ថុ** ៖ ស្តីពីការផ្សព្វផ្សាយបញ្ជីឈ្មោះអ្នកទទួលការដែលត្រូវបានដាក់ក្នុងបញ្ជីខ្មៅ ឬត្រូវបានហាមឃាត់មិនឱ្យដាក់សំណើដេញថ្លៃកិច្ចសន្យាឃុំ សង្កាត់។

**យោង** ៖ - សេចក្តីសម្រេចលេខ ០៩៧ សសរ/គ.ជ.អ.ប ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

- លិខិតលេខ៤៣៧ សជណ/អរប ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ
- បំណាជ់ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៥។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈ-អភិបាលរាជធានី ខេត្ត** ជ្រាបថា បន្ទាប់ពីទទួលបានបញ្ជីឈ្មោះអ្នកទទួលការដែលត្រូវបានដាក់ក្នុងបញ្ជីខ្មៅ ឬត្រូវបានហាមឃាត់មិនឱ្យដាក់សំណើដេញថ្លៃកិច្ចសន្យាឃុំ សង្កាត់ ដែលនៅមានសុពលភាពពីរដ្ឋបាលរាជធានី ខេត្តទាំង២៥រួចមក អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ បានពិនិត្យ និងរៀបចំចងក្រងបញ្ជីឈ្មោះអ្នកទទួលការដែលត្រូវបានដាក់ក្នុងបញ្ជីខ្មៅ ឬត្រូវបានហាមឃាត់មិនឱ្យដាក់សំណើដេញថ្លៃកិច្ចសន្យាឃុំ សង្កាត់ដែលនៅមានសុពលភាព ក្នុងតារាងរួមតែមួយ។ ក្នុងស្មារតីនេះ ដើម្បីពង្រឹងលើការគ្រប់គ្រង និងការចែករំលែកព័ត៌មានអំពីអ្នកទទួលការដែលត្រូវបានដាក់ក្នុងបញ្ជីខ្មៅ ឬត្រូវបានហាមឃាត់មិនឱ្យដាក់សំណើដេញថ្លៃកិច្ចសន្យាឃុំ សង្កាត់ ឱ្យកាន់តែទូលំទូលាយ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ សូមស្នើ **ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត** ចាត់ចែងផ្សព្វផ្សាយនូវបញ្ជីឈ្មោះអ្នកទទួលការដែលត្រូវបានដាក់ក្នុងបញ្ជីខ្មៅ ឬត្រូវបានហាមឃាត់មិនឱ្យដាក់សំណើដេញថ្លៃកិច្ចសន្យាឃុំ សង្កាត់នេះដល់គ្រប់រដ្ឋបាលឃុំ សង្កាត់ក្នុងរាជធានី ខេត្តរបស់ខ្លួន។

សូមជូនភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះអ្នកទទួលការដែលត្រូវបានដាក់ក្នុងបញ្ជីខ្មៅ ឬត្រូវបានហាមឃាត់មិនឱ្យដាក់សំណើដេញថ្លៃកិច្ចសន្យាឃុំ សង្កាត់ដែលនៅមានសុពលភាពចំនួន១ច្បាប់។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត** ជ្រាប និងចាត់ចែងផ្សព្វផ្សាយឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវការរាប់អានពីខ្ញុំ។

អគ្គនាយក
រ.ទ.ក
ហត្ថលេខា

**សុខ ធារា**

**ចម្លងជូន:-**
- ខុទ្ទកាល័យឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- ឯកសារ កាលប្បវត្តិ

## បញ្ជីឈ្មោះអ្នកទទួលការដែលត្រូវបានដកសិទ្ធិមិនឱ្យដាក់សំណើដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ ឬធ្វើជាតំណាងក្រុមហ៊ុនណាមួយក្នុងការដាក់សំណើដេញថ្លៃកិច្ចសន្យាឃុំ សង្កាត់ ឬធ្វើជាអ្នកទទួលការបន្តក្នុងការអនុវត្តកិច្ចសន្យាឃុំ សង្កាត់

| ល.រ | ឈ្មោះក្រុមហ៊ុន | ឈ្មោះប្រធានក្រុមហ៊ុន | ចុះឈ្មោះនៅរាជធានី ខេត្ត | កាលបរិច្ឆេទនៃការសម្រេចដកសិទ្ធិ | យោងសេចក្តីសម្រេចលេខ | មូលហេតុដែលបរិយាយអ្នកទទួលការត្រូវបានដកសិទ្ធិ | មិនឱ្យចូលរួមដេញថ្លៃនៅរាជធានី ខេត្ត | កាលបរិច្ឆេទផុតរយៈពេលដកសិទ្ធិ |
|---|---|---|---|---|---|---|---|---|
| ១ | គុង អេន | គៅ ធេន | កំពត | ១២ មេសា ២០២៣ | ០៩៤/២៣ សសរ | ក្រុមហ៊ុនមិនមកចុះកិច្ចសន្យាតាមការអញ្ជើញរបស់រដ្ឋបាលឃុំអូរសំព័រ | បន្ទាយមានជ័យ | ជារៀងរហូត |
| ២ | ស៊ិម វឌ្ឍនា | ស៊ិម វឌ្ឍនា | បន្ទាយមានជ័យ | ១ វិច្ឆិកា ២០២១ | ៤១៩/២១ សសរ | ក្រុមហ៊ុនមានចេតនាអូសទាញឃុំឱ្យអនុវត្តខុសពីកិច្ចសន្យា និងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ | បន្ទាយមានជ័យ | ជារៀងរហូត |
| ៣ | សេង ច័ន្ទដារី | សេង ច័ន្ទដារី | កំពង់ចាម | ១០ ឧសភា ២០១៩ | ០៦២/១៩ សសរ | ក្រុមហ៊ុនបានប្រព្រឹត្តសកម្មភាពមួយចំនួនមិនប្រក្រតីពីការដេញថ្លៃគម្រោងមូលនិធិឃុំ នៅសាលាស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម | កំពង់ចាម | ជារៀងរហូត |
| ៤ | អាន សុខលាង | អាន សុខលាង | កោះកុង | ១៦ កក្កដា ២០២០ | ៨៧/២០ សសរ | ក្រុមហ៊ុនមានចេតនាមកបង្កភាពអុកឡុកកិច្ចប្រជុំបើកសំណើដេញថ្លៃគម្រោងមូលនិធិឃុំ នៅស្រុកចំការលើ | កំពង់ចាម | ជារៀងរហូត |
| ៥ | ប៉ូច ក្វាត់ | ប៉ូច ក្វាត់ | កំពង់ឆ្នាំង | ៣០ កក្កដា ២០២១ | ២២៥/២១ សសរ | ក្រុមហ៊ុនមានចេតនាមកបង្កភាពអុកឡុកកិច្ចប្រជុំបើកសំណើដេញថ្លៃគម្រោងមូលនិធិឃុំ នៅស្រុកជើងព្រៃ | កំពង់ចាម | ជារៀងរហូត |
| ៦ | យឹម សុកខេន | យឹម សុកខេន | កណ្តាល | ២ សីហា ២០២៤ | ០៨៨/២៤ សសរ | ក្រុមហ៊ុនមានចេតនាមកបង្កភាពអុកឡុកកិច្ចប្រជុំបើកសំណើដេញថ្លៃគម្រោងមូលនិធិឃុំ នៅស្រុកកោះសូទិន | កំពង់ចាម | ជារៀងរហូត |
| ៧ | ឆាង ដានី | ឆាង ដានី | កណ្តាល | ១៩ កក្កដា ២០២៤ | ០៥១ សសរ | ក្រុមហ៊ុនមិនព្រមចុះកិច្ចសន្យានៅក្នុងអំឡុងពេលសុពលភាពនៃសំណើដេញថ្លៃ | ទូទាំងប្រទេស | ២៥ កក្កដា ២០២៦ |
| ៨ | សេង វុទ្ធី | សេង វុទ្ធី | កណ្តាល | ២៧ ធ្នូ ២០២៤ | ១៤៩ សសរ | ក្រុមហ៊ុនបានដាក់សំណើដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់បានតិចជាង៣សំណើក្នុងឆ្នាំ២០២៤ (បានដាក់០សំណើ) | ទូទាំងប្រទេស | ១ឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខា |
| ៩ | ធី.អិល.អេស | ថេង លាងសេង | កណ្តាល | ២៧ ធ្នូ ២០២៤ | ១៤៩ សសរ | ក្រុមហ៊ុនបានដាក់សំណើដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់បានតិចជាង៣សំណើក្នុងឆ្នាំ២០២៤ (បានដាក់២សំណើ) | ទូទាំងប្រទេស | ១ឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខា |

| ល.រ | ឈ្មោះក្រុមហ៊ុន | ឈ្មោះប្រធានក្រុមហ៊ុន | ចុះឈ្មោះនៅរាជធានី ខេត្ត | កាលបរិច្ឆេទនៃការសម្រេចដកសិទ្ធិ | យោងសេចក្ដីសម្រេចលេខ | មូលហេតុដែលបណ្ដាលឱ្យអ្នកទទួលការត្រូវបានដកសិទ្ធិ | មិនឱ្យចូលរួមដេញថ្លៃនៅរាជធានី ខេត្ត | កាលបរិច្ឆេទផុតរយៈពេលដកសិទ្ធិ |
|---|---|---|---|---|---|---|---|---|
| ១០ | ប៉ាល់ ភន់ ខន ស្ពាក់សិន ឯ.ក | ប៉ាល់ ភន់ | កណ្ដាល | ២៧ ធ្នូ ២០២៤ | ១៤៩ សសរ | ក្រុមហ៊ុនបានដាក់សំណើដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់បានតិចជាង ៣សំណើក្នុងឆ្នាំ២០២៤ (បានដាក់០សំណើ) | ទូទាំងប្រទេស | ១ឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខា |
| ១១ | យឹម សុខខេន | យឹម សុខខេន | កណ្ដាល | ២៧ ធ្នូ ២០២៤ | ១៤៩ សសរ | ក្រុមហ៊ុនបានដាក់សំណើដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់បានតិចជាង ៣សំណើក្នុងឆ្នាំ២០២៤ (បានដាក់០សំណើ) | ទូទាំងប្រទេស | ១ឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខា |
| ១២ | ប្រាយម៍ អេសអេសកី (ខេមបូឌា) | ហេង ថារី | កណ្ដាល | ២៧ ធ្នូ ២០២៤ | ១៤៩ សសរ | ក្រុមហ៊ុនបានដាក់សំណើដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់បានតិចជាង ៣សំណើក្នុងឆ្នាំ២០២៤ (បានដាក់២សំណើ) | ទូទាំងប្រទេស | ១ឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខា |
| ១៣ | លឹម អ៊ូ | លឹម អ៊ូ | កណ្ដាល | ២៧ ធ្នូ ២០២៤ | ១៤៩ សសរ | ក្រុមហ៊ុនបានដាក់សំណើដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់បានតិចជាង ៣សំណើក្នុងឆ្នាំ២០២៤ (បានដាក់០សំណើ) | ទូទាំងប្រទេស | ១ឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខា |
| ១៤ | អ៊ូ ចំណាន | អ៊ូ ចំណាន | កណ្ដាល | ២៧ ធ្នូ ២០២៤ | ១៤៩ សសរ | ក្រុមហ៊ុនបានដាក់សំណើដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់បានតិចជាង៣សំណើក្នុងឆ្នាំ២០២៤ (បានដាក់១សំណើ) | ទូទាំងប្រទេស | ១ឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខា |
| ១៥ | យឹម សុភ័ក្ត | យឹម សុភ័ក្ត | ក្រចេះ | ១២ កក្កដា ២០១៩ | ០៤៨/១៩ សសរ | ក្រុមហ៊ុន បានក្លែងបន្លំលិខិតធានាប្រាក់កក់ធានាការអនុវត្តគម្រោងឃុំឫស្សីកែវ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ | ទូទាំងប្រទេស | ជារៀងរហូត |
| ១៦ | ហួត គ្រីវ៉ាន់ | ហួត គ្រីវ៉ាន់ | ក្រចេះ | ២៧ កញ្ញា ២០២៤ | ០៦០/២៤ សសរ | ក្រុមហ៊ុនមិនទទួលយកកិច្ចសន្យាដែលបានដេញថ្លៃឈ្នះនៃគម្រោងសាងសង់ផ្លូវបេតុងអាមេប្រវែង០.២៥គម ទទឹង៥ម និងកម្រាស់ ០.១៥ម ឆ្នាំ២០២៤ របស់រដ្ឋបាលឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ | ទូទាំងប្រទេស | ១០ខែ ចាប់ពីថ្ងៃចុះហត្ថលេខា |
| ១៧ | នួន សុគន្ធ | នួន សុគន្ធ | មណ្ឌលគិរី | ១៩ សីហា ២០២៤ | ០៣១/២៤ សសរ | ក្រុមហ៊ុនបានដេញថ្លៃឈ្នះនៅសង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ គម្រោងមូលនិធិសង្កាត់ឆ្នាំ២០២៤ មិនព្រមទទួលចុះកិច្ចសន្យាអនុវត្តគម្រោង | មណ្ឌលគិរី | ជារៀងរហូត |
| ១៨ | លឹម វ៉េងហួត | លឹម វ៉េងហួត | កំពង់ឆ្នាំង | ៣ កក្កដា ២០២៣ | ០៤៩/២៣ សសរ | ក្រុមហ៊ុនប្រើប្រាស់ឯកសារពុំត្រឹមត្រូវ និងមានអាកប្បកិរិយាមិនសមរម្យផ្ទុយពីគោលការណ៍ និងបទបញ្ជាផ្ទៃក្នុងនៃការដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ | ព្រះវិហារ | ជារៀងរហូត |

| ល.រ | ឈ្មោះក្រុមហ៊ុន | ឈ្មោះប្រធានក្រុមហ៊ុន | ចុះឈ្មោះនៅរាជធានី ខេត្ត | កាលបរិច្ឆេទនៃការសម្រេចដកសិទ្ធិ | យោងសេចក្តីសម្រេចលេខ | មូលហេតុដែលបណ្តាលឱ្យអ្នកទទួលការត្រូវបានដកសិទ្ធិ | មិនឱ្យចូលរួមដេញថ្លៃនៅរាជធានី ខេត្ត | កាលបរិច្ឆេទផុតរយៈពេលដកសិទ្ធិ |
|---|---|---|---|---|---|---|---|---|
| ១៩ | ទ្រី សុឃី | ទ្រី សុឃី | ភ្នំពេញ | ៣ កក្កដា ២០២៣ | ០៤៨/២៣ សសរ | ក្រុមហ៊ុនបានប្រព្រឹត្តផ្ទុយសេចក្តីប្រកាសស្តីពីក្រមសីលធម៌ ការមិនក្លែងបន្លំ និងការមិនប្រព្រឹត្តអំពើពុករលួយ និងប្រើប្រាស់ឯកសារពុំត្រឹមត្រូវក្នុងកិច្ចលទ្ធកម្មគម្រោងមូលនិធិឃុំគូលែនត្បូង | ព្រះវិហារ | ជារៀងរហូត |
| ២០ | ញ៉ែម ចិន្តា | ញ៉ែម ចិន្តា | កណ្តាល | ៨ មករា ២០១៩ | ០០១/១៩ សសរ | ក្រុមហ៊ុនមិនបានមកចុះកិច្ចសន្យាគម្រោងមូលនិធិឃុំតាមការជូនដំណឹងរបស់រដ្ឋបាលឃុំម្លូព្រៃពីរ ស្រុកឆែប ខេត្តព្រះវិហារ | ព្រះវិហារ | ជារៀងរហូត |
| ២១ | សំណង់ជា សុងលី | ជា សុងលី | កំពង់ស្ពឺ | ២៧ កញ្ញា ២០២២ | ០៣៨/២២ សសរ | ក្រុមហ៊ុនពុំបានបំពេញតម្លៃឯកតាក្នុងសំណើដេញថ្លៃ ពុំមានសេចក្តីប្រកាសស្តីពីក្រមសីលធម៌ ការមិនក្លែងបន្លំ និងការមិនប្រព្រឹត្តអំពើពុករលួយ ពុំមានលិខិតផ្ទេរសិទ្ធិ និងរចនាសម្ព័ន្ធរបស់ក្រុមហ៊ុន | ព្រះវិហារ | ជារៀងរហូត |
| ២២ | វ៉េង ណាប | វ៉េង ណាប | កណ្តាល | ១៧ តុលា ២០២៤ | ០៨៨/២៤ សសរ | ក្រុមហ៊ុនបានអនុវត្តខុសពីនីតិវិធីលទ្ធកម្មគម្រោងមូលនិធិឃុំ សង្កាត់ ដោយបង្ខំគណៈកម្មការលទ្ធកម្មឃុំឱ្យអនុវត្តខុសពីនីតិវិធី តែគណៈកម្មការលទ្ធកម្មមិនព្រម ហើយសុំថតសំណុំឯកសារដេញថ្លៃក្រុមហ៊ុនដែលបានដាក់សំណើដេញថ្លៃ និងបង្កការអុកឡុកយ៉ាងអនាធិបតេយ្យ មិនគោរពតាមនីតិវិធីគោលការណ៍ណែនាំ ដូចមានចែងក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន | ព្រះវិហារ | ជារៀងរហូត |
| ២៣ | អ៊ូ ស៊ុនហៀង | អ៊ូ ស៊ុនហៀង | ឧត្តរមានជ័យ | ១៧ តុលា ២០២៤ | ០៨៩/២៤ សសរ | ក្រុមហ៊ុនបានអនុវត្តខុសពីនីតិវិធីលទ្ធកម្មគម្រោងមូលនិធិឃុំ សង្កាត់ ដោយបង្ខំគណៈកម្មការលទ្ធកម្មឃុំឱ្យអនុវត្តខុសពីនីតិវិធី តែគណៈកម្មការលទ្ធកម្មមិនព្រម ហើយសុំថតសំណុំឯកសារដេញថ្លៃក្រុមហ៊ុនដែលបានដាក់សំណើដេញថ្លៃ និងបង្កការអុកឡុកយ៉ាងអនាធិបតេយ្យ មិនគោរពតាម នីតិវិធីគោលការណ៍ណែនាំ ដូចមានចែងក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន | ព្រះវិហារ | ជារៀងរហូត |

| ល.រ | ឈ្មោះក្រុមហ៊ុន | ឈ្មោះប្រធានក្រុមហ៊ុន | ចុះឈ្មោះនៅរាជធានី ខេត្ត | កាលបរិច្ឆេទនៃការសម្រេចដកសិទ្ធិ | យោងសេចក្តីសម្រេចលេខ | មូលហេតុដែលបណ្តាលឱ្យអ្នកទទួលការត្រូវបានដកសិទ្ធិ | មិនឱ្យចូលរួមដេញថ្លៃនៅរាជធានី ខេត្ត | កាលបរិច្ឆេទផុតរយៈពេលដកសិទ្ធិ |
|---|---|---|---|---|---|---|---|---|
| ២៤ | សរ ណាន់គ្រុប | សរ ណាន់ | ភ្នំពេញ | ៥ វិច្ឆិកា ២០២២ | ០៥៣/២៣ សសរ | ក្រុមហ៊ុនមិនអនុវត្តគោរពតាមលក្ខខណ្ឌកិច្ចសន្យានៃគម្រោងស្ពានប្រឡាយ ប្រវែង៤៤៥០ម៉ែត្រ ១ទឹងបាត២ម៉ែត្រ ឆ្នាំ២០២២ នៅឃុំរំចេក ស្រុកព្រះស្ដេច ខេត្តព្រៃវែង | ព្រៃវែង | ជារៀងរហូត |
| ២៥ | យឹម គឿន | យឹម គឿន | ព្រៃវែង | ២៧ មេសា ២០២០ | ០៨៤/២០ សសរ | ក្រុមហ៊ុនមិនអនុវត្តគោរពតាមលក្ខខណ្ឌកិច្ចសន្យានៃគម្រោងស្ពានប្រឡាយ ប្រវែង២០៣៧ម៉ែត្រ ខ្នងលើ៤ម៉ែត្រ ឆ្នាំ២០១៧ នៅសង្កាត់តាកោ ក្រុងព្រៃវែង ខេត្តព្រៃវែង | ព្រៃវែង | ជារៀងរហូត |
| ២៦ | ហួត ឡូត | ហួត ឡូត | ស្ទឹងត្រែង | ២៥ កុម្ភៈ ២០១៩ | ០៨១/១៩ សសរ | ក្រុមហ៊ុនមិនអនុវត្តគោរពតាមលក្ខខណ្ឌកិច្ចសន្យានៃគម្រោងជួសជុលផ្លូវដីសប្រវែង ៣៥៥០ម៉ែត្រ ខ្នងលើ៤ម៉ែត្រ ឆ្នាំ២០១៧ ឃុំថ្មពូន ស្រុកកញ្ជៀច ខេត្តព្រៃវែង | ព្រៃវែង | ជារៀងរហូត |
| ២៧ | សំណង់ ជីវ៉ូ | ជី វ៉ូ | កណ្ដាល | ២៨ កក្កដា ២០២៣ | ០៥៤/២៣ សសរ | ក្រុមហ៊ុនបានដេញថ្លៃមិនមានតម្លាភាព មានការឃុបឃិតគ្នា ដោយមានការចំណាយប្រាក់ដើម្បីផ្ដល់ឱ្យទៅក្រុមហ៊ុនផ្សេងៗដែលមានបំណងចូលរួមដេញថ្លៃ ឱ្យដកខ្លួនមិនចូលរួមដេញថ្លៃ | ព្រះសីហនុ | ជារៀងរហូត |
| ២៨ | សុធីរាជ ឃិនស្រ្តាក់ស្ទិន | ម៉ៅ អេងជី | កំពង់ចាម | ៥ មករា ២០២៣ | ០០១/២៤ សសរ | ក្រុមហ៊ុនបានចូលរួមអនុវត្តគម្រោងចរចាបន្ថែមលទ្ធផលកិច្ចសន្យាដែលមានតម្លៃឯកតាខ្ពស់ជាងតម្លៃឯកតានៃសំណើដេញថ្លៃឈ្នះរបស់ខ្លួន នៅក្នុងឃុំសេកុង និងឃុំស្រែសំបូរ ស្រុកសៀមប៉ាង | ស្ទឹងត្រែង | ជារៀងរហូត |
| ២៩ | សូ សុផាក់ ឯ.ក | សូ សុផាក់ | ស្វាយរៀង | ២៦ មិថុនា ២០២៤ | ០៨៧/២៤ សសរ | ក្រុមហ៊ុនបានដេញថ្លៃឈ្នះនៅឃុំអង្គប្រស្រែ ស្រុករមាសហែក ខេត្តស្វាយរៀង រួចហើយ មិនព្រមទទួលចុះកិច្ចសន្យាសាងសង់ | ស្វាយរៀង | ជារៀងរហូត |
| ៣០ | នេត ស្រីខួច | សេង ស៊ីនេត | កំពត | ២៥ តុលា ២០២២ | ០៦៥ សសរ | ក្រុមហ៊ុនបានដេញថ្លៃឈ្នះមិនព្រមទទួលយកកិច្ចសន្យាអនុវត្តគម្រោង | តាកែវ | ជារៀងរហូត |
| ៣១ | គ្រីស ហេង | គ្រីស ហេង | កំពត | ២៥ តុលា ២០២២ | ០៦៦ សសរ | ក្រុមហ៊ុនបានដេញថ្លៃឈ្នះមិនព្រមទទួលយកកិច្ចសន្យាអនុវត្តគម្រោង | តាកែវ | ជារៀងរហូត |
| ៣២ | សំណង់ហ៊ាប់ហ៊ | ឌុល សេងហាប់ | កំពត | ២២ វិច្ឆិកា ២០១៦ | ១២៤ សសរ | ក្រុមហ៊ុនចុះកិច្ចសន្យារួចហើយមិនអនុវត្តគម្រោងតាមផែនការការងាររបស់ខ្លួន | តាកែវ | ជារៀងរហូត |

| ល.រ | ឈ្មោះក្រុមហ៊ុន | ឈ្មោះប្រធានក្រុមហ៊ុន | ចុះឈ្មោះនៅរាជធានី ខេត្ត | កាលបរិច្ឆេទនៃការសម្រេចដកសិទ្ធិ | យោងសេចក្ដីសម្រេចលេខ | មូលហេតុដែលបរិយាយអ្នកទទួលការត្រូវបានដកសិទ្ធិ | មិនឱ្យចូលរួមដេញថ្លៃនៅរាជធានី ខេត្ត | កាលបរិច្ឆេទផុតរយៈពេលដកសិទ្ធិ |
|---|---|---|---|---|---|---|---|---|
| ៣៣ | វ៉ែន ចំរើន | វី គង់ | ឧត្តរមានជ័យ | ៤ មេសា ២០២៤ | ០៣១/២៤ សសរ/ឧជ | ក្រុមហ៊ុនអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់មិនទាន់ពេលវេលា ស្របតាមផែនការការងារ ដូចមានចែងនៅក្នុងកិច្ចសន្យាគម្រោង | ឧត្តរមានជ័យ | ជារៀងរហូត |
| ៣៤ | តាំង គឹមសឿន | តាំង គឹមសឿន | ឧត្តរមានជ័យ | ៤ មេសា ២០២៤ | ០៣១/២៤ សសរ/ឧជ | ក្រុមហ៊ុនអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ព្យាយាមលួចបន្លំគុណភាពសំណង់ | ឧត្តរមានជ័យ | ជារៀងរហូត |
| ៣៥ | ម៉ាត់ គ្រីយ៉ា | ម៉ាត់ គ្រីយ៉ា | មណ្ឌលគិរី | ១៤ មិថុនា ២០២៣ | ០៥៣/២៣ សសរ.តយ | បុគ្គលឈ្មោះម៉ាត់ គ្រីយ៉ា មានចេតនាក្លែងបន្លំឯកសារដែលមិនមានលក្ខណៈត្រឹមត្រូវទៅកក់ប្រាក់ធានាការដេញថ្លៃ ដោយបន្លំធនាគារថា ក្រុមហ៊ុនខ្លួនមានសម្បទាគ្រប់គ្រាន់អាចចូលរួមដេញថ្លៃគម្រោងមូលនិធិឃុំ ដែលមានប្រភេទទី១ ប្រភេទទី២ និងប្រភេទទី៣ ក្នុងគោលបំណង បង្កការអុកឡុកភាពអនាធិបតេយ្យ និងរំខានដល់ដំណើរការនៃកិច្ចលទ្ធកម្មគម្រោងមូលនិធិឃុំទួលស្ដួលកាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣ នៅសាលាឃុំទួលស្ដួល ស្រុកក្រូចឆ្មារ | ត្បូងឃ្មុំ | ជារៀងរហូត |
| ៣៦ | ជា កក្កដា | ជា កក្កដា | ត្បូងឃ្មុំ | ២៩ កញ្ញា ២០២១ | ២០៩/២១ សសរ | បុគ្គលឈ្មោះ ជា កក្កដា មិនបានគោរពតាមគោលការណ៍ណែនាំស្ដីពីការបង្ការនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ បំពានទៅលើក្រុមការងារសណ្ដាប់ធ្នាប់សុវត្ថិភាព និងបានរុញទ្វារចូលក្នុងបរិវេណសាលាឃុំ នៅអំឡុងពេលនៃកិច្ចដំណើរការលទ្ធកម្ម ក្នុងគោលបំណងបង្កភាពអនាធិបតេយ្យ ដល់ដំណើរការនៃកិច្ចលទ្ធកម្មគម្រោងមូលនិធិឃុំជំនីក កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ នៅសាលាឃុំជំនីក ស្រុកក្រូចឆ្មារ | ត្បូងឃ្មុំ | ៥ឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខា |

| ល.រ | ឈ្មោះក្រុមហ៊ុន | ឈ្មោះប្រធានក្រុមហ៊ុន | ចុះឈ្មោះនៅរាជធានី ខេត្ត | កាលបរិច្ឆេទនៃការសម្រេចដកសិទ្ធិ | យោងសេចក្តីសម្រេចលេខ | មូលហេតុដែលបរិយាយអ្នកទទួលការគ្រូវបានដកសិទ្ធិ | មិនឱ្យចូលរួមដេញថ្លៃនៅរាជធានី ខេត្ត | កាលបរិច្ឆេទផុតរយៈពេលដកសិទ្ធិ |
|---|---|---|---|---|---|---|---|---|
| ៣៧ | កែម សុផល | កែម សុផល | កំពង់ចាម | ១០ សីហា ២០២១ | ១៦៦/២១ សសរ/គយ | ក្រុមហ៊ុនកែម សុផល បានផ្ទេរសិទ្ធិឱ្យបុគ្គលឈ្មោះ មឿន ចាន់ណា ភេទប្រុស អាយុ៣១ឆ្នាំ ជាតំណាងចូលរួមក្នុងការដេញថ្លៃគម្រោងមូលនិធិឃុំរំចេក ឃុំគគីរ និងឃុំមេមង កាលថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ នៅសាលាស្រុកមេមត់។ បុគ្គលឈ្មោះ មឿន ចាន់ណា មិនគោរពតាមបទបញ្ជាផ្ទៃក្នុង និងមិនស្តាប់ការអានគោលការណ៍ណែនាំស្តីពីការដេញថ្លៃរបស់គណៈកម្មការលទ្ធកម្ម ជាពិសេសបុគ្គលនេះបានបង្កភាពអនាធិបតេយ្យដោយគិតតែពីលួចថតរូបភាពជាច្រើនក្នុងគោលបំណងមិនល្អ និងមានចេតនាបង្កភាពអុកឡុក រំខានដល់ដំណើរការនៃកិច្ចលទ្ធកម្មគម្រោងមូលនិធិឃុំ | ត្បូងឃ្មុំ | ជារៀងរហូត |

ថ្ងៃ[illegible] ខែ [illegible] ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០២៥

**អគ្គនាយកដ្ឋានរដ្ឋបាល**